# និន្នាការសេដ្ឋកិច្ច-សង្គម

## Socio-Economic Trends

## ខែតុលា ឆ្នាំ២០២១ / October 2021

**មាតិកា**


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **២** |
|    ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ២ |
|    ១.២. វិស័យពាណិជ្ជកម្ម/Trade | ៣ |
|    ១.៣. វិស័យវិនិយោគឯកជន/Private investment | ៤ |
|    ១.៤. វិស័យទេសចរណ៍/Tourism | ៤ |
|    ១.៥ វិស័យសំណង់/Construction | ៥ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗ/Commodity prices** | **៥** |
|    ២.១. ថ្លៃប្រេង (Crude oil price: Brent, WTI, Dubai) | ៥ |
|    ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ៦ |
|    ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ៦ |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
Phone: (+855)23 890 666

## ខ្លឹមសារសង្ខេប / Executive summary

១.ក្នុងខែតុលា ឆ្នាំ២០២១, សេដ្ឋកិច្ចប្រទេសកម្ពុជាបានបង្ហាញពីភាពប្រសើរឡើងវិញបន្តិចម្តងៗ ប៉ុន្តែពុំទាន់អាចវិលមករកភាពប្រក្រតីភាពដូចកាលមុនមានការរីករាលដាលនៃជំងឺកូវីដ-១៩ នៅឡើយទេ ។ បន្ទាប់ពីការទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ជាពិសេស ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈកន្លងមក បានបង្ហាញថា, សូចនាករសំខាន់ៗ នៃវិស័យកំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានទទួលរងសម្ពាធរួមមាន÷ ចំនួនភ្ញៀវទេសចរជាតិនិងអន្តរជាតិ, សកម្មភាពនៅក្នុងវិស័យសំណង់ និងទុនវិនិយោគពីបរទេស បាននិងកំពុងបន្តធ្លាក់ចុះ ។ ទោះបីជាយ៉ាងនេះក្តី, ការនាំចេញក្រៅពីសម្លៀកបំពាក់និងផលិតផលកាត់ដេរ ដូចជា កង់, គ្រឿងបង្គុំអេឡិចត្រូនិក, ផលិតផលពីឈើ និងផលិតផលកសិកម្មផ្សេងទៀត ជាដើម បានបន្តរក្សាកំណើនល្អ ខណៈដែលការនាំចេញសម្លៀកបំពាក់ និងផលិតផលកាត់ដេរ បានសន្ទុះងើបឡើងវិញគួរឱ្យកត់សម្គាល់ ។ ជារួម សេដ្ឋកិច្ចកម្ពុជា រំពឹងថានឹងមានកំណើនវិជ្ជមានក្នុងឆ្នាំ២០២១ ដោយសារការងើបឡើងវិញនៃស្ថានភាពសេដ្ឋកិច្ចសកល, សេដ្ឋកិច្ចដៃគូពាណិជ្ជកម្មរបស់កម្ពុជា, និងការចូលរួមពីប្រជាជនកម្ពុជាក្នុងការបំពេញកាតព្វកិច្ចចាក់វ៉ាក់សាំងដើម្បីការពារជំងឺកូវីដ-១៩ និងការគោរពតាមគោលការណ៍ ៣កុំ ៣ការពារ បូករួមជាមួយនឹងការជម្រុញពីវិស័យមួយចំនួន រួមមាន វិស័យកសិកម្ម, វិស័យកម្មន្តសាលមិនមែនកាត់ដេរ, វិស័យទឹកជញ្ជូន និងគមនាគមន៍ និងលទ្ធភាពនៃការបង្វែរការបញ្ជារទិញ និងរោងចក្រកាត់ដេរពីប្រទេសមីយ៉ាន់ម៉ាមកកាន់ប្រទេសកម្ពុជា ។

២.ក្នុងខែតុលា ឆ្នាំ២០២១, ប្រេងសាំងថ្លៃជាមធ្យម ៤ ២០០៛/ល កើនឡើង ៦,៣% និងប្រេងម៉ាស៊ូតថ្លៃជាមធ្យម ៣ ៩០០៛/ល កើនឡើង ៩,១% ធៀបនឹងខែកញ្ញា ។ ទន្ទឹមនេះ នៅលើទីផ្សារអន្តរជាតិ ប្រេងឆៅ (Brent) ថ្លៃមធ្យម ៨៣,៧ ដុល្លារ/បារ៉ែល កើនឡើង ១២,១% និងប្រេងឆៅ (WTI) ថ្លៃមធ្យម ៨១,៣ ដុល្លារ/បារ៉ែល កើនឡើង ១៣,៦% ធៀបខែកញ្ញា ។

៣.រយៈពេល ១០ ខែ ឆ្នាំ២០២១, ការនាំចេញទំនិញ (ដកមាស)សម្រេចបានក្នុងទំហំទឹកប្រាក់ចំនួន ១៤.១៨១ លានដុល្លារ បានកើនឡើង ២២,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដោយសារកំណើននាំចេញផលិតផលវាយនភណ្ឌ, កង់ និង ទំនិញផ្សេងៗ ដូចជា គ្រឿងសង្ហារឹម, ស្បែកសត្វមានរោម (furskins), កៅស៊ូ, ក្ដារកុងប្លាកេ, វត្ថុសម្រាប់ជាងសំណង់ធ្វើពីប្លាស្ទិក, សូឡា, ខ្សែភ្លើងនិងបង្គុំខ្សែភ្លើង, គ្រឿងអេឡិចត្រូនិកនិងភាគបំណែក, ចេក, ស្ករស, កសិផលផ្សេងៗ, ដំឡូងមី និង ស្វាយ។ ទន្ទឹមនេះ ការនាំចូលទំនិញ(ដកមាសចេញ) សម្រេចបានក្នុងទំហំទឹកប្រាក់១៨,៤ ប៊ីលានដុល្លារ(ស្មើនឹង ៦៤,២% នៃផសស) បានកើនឡើង ២៦,១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដោយសារកំណើននៃការនាំចូលក្រណាត់, គ្រឿងសំណង់, ប្រេងឥន្ទនៈ និង ទំនិញផ្សេងៗ ។

៤.រយៈពេល ១០ខែ ឆ្នាំ២០២១, ស្ថានភាពភ្ញៀវទេសចរ នៅតែបន្តធ្លាក់ចុះ, ជាក់ស្តែងកម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិសរុបចំនួន ១៤៤ ពាន់នាក់ បានធ្លាក់ចុះ ៨៨,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ ភ្ញៀវទេសចរចិនមានចំនួន ៤០ ពាន់នាក់ (ស្មើ ២៧,៥% នៃភ្ញៀវទេសចរអន្តរជាតិសរុប) បានធ្លាក់ចុះ ៨៨,៦% ។

៥.រយៈពេល ១០ខែ ឆ្នាំ២០២១, ចំនួនគម្រោងដែលទទួលបានការអនុញ្ញាតសាងសង់សរុបមាន ៣ ៥៩៨ គម្រោង បានធ្លាក់ចុះ ៤៨២ គម្រោង និងតម្លៃគម្រោងសរុបមាន ៥ ១២៣ លានដុល្លារ បានធ្លាក់ចុះ ១៦,៦% ក្នុងនោះ ប្រភេទសំណង់លំនៅដ្ឋានមាន ៣ ១០៩ គម្រោង (ស្មើនឹង ៨៦,៤% នៃសំណើសុំសាងសង់សរុប) បានធ្លាក់ចុះ ៣៣៦ គម្រោង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។

៦.រយៈពេល ១០ ខែ ឆ្នាំ២០២១, ស្ថានភាពវិនិយោគ មិនទាន់មានភាពល្អប្រសើរនៅឡើយទេ, ជាក់ស្តែងគម្រោងវិនិយោគឯកជនសរុប[1] មានចំនួន ៩២ គម្រោង បានធ្លាក់ចុះ ៣៧ គម្រោង, លទ្ធភាពបង្កើតកម្លាំងពលកម្មថ្មីប្រមាណជា ៧៣ពាន់នាក់ បានធ្លាក់ចុះ ២៩,៨% និង ទុនវិនិយោគសរុប ១ ១៦៦ លានដុល្លារ បានធ្លាក់ចុះ ៨១,៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន[2] ។

៧. នៅខែតុលា ឆ្នាំ២០២១, សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញ កើនឡើង ២,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ កំណើននេះ គឺដោយសារការកើនឡើងនៃសន្ទស្សន៍ថ្លៃម្ហូបអាហារ ២,១%, សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើង ៤,៥%, សន្ទស្សន៍ថ្លៃផ្ទះសំបែង, ទឹក, អគ្គិសនី, ឧស្ម័ន និងឥន្ធនៈដទៃទៀត ៣,០%, សន្ទស្សន៍ថ្លៃក្រុមដឹកជញ្ជូន ១២,៣% និង សន្ទស្សន៍ទំនិញនិងសេវាកម្មផ្សេងៗ ៥,១%។

---

[1] គម្រោងវិនិយោគឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

2 ទិន្នន័យនេះពុំមានបូករួមបញ្ចូលទិន្នន័យរបស់តំបន់សេដ្ឋកិច្ចទេ

# ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

## ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index







ប្រភព: វិទ្យាស្ថានជាតិស្ថិតិ

## ១.២. វិស័យពាណិជ្ជកម្ម / Trade



ក្រាហ្វិច ៤៖ ទឹកប្រាក់នាំចេញ (ដកមាស) ក្នុងរយៈពេល ១០ខែ ឆ្នាំ២០២១ បានកើនឡើងធៀបនឹងបណ្ដាឆ្នាំមុនៗ




ក្រាហ្វិច ៥៖ កំណើនល្អនៃការនាំចេញផលិតផលវាយនភណ្ឌ, កង់ និងទំនិញផ្សេងៗ បានធ្វើឱ្យការនាំចេញសរុបកើនឡើង (ដកមាស)




ក្រាហ្វិច ៦៖ ទីផ្សារអាមេរិក, អឺរ៉ុប និង ចិនបានរួមចំណែកធំក្នុងទីផ្សារនាំចេញសរុបរបស់កម្ពុជា




ក្រាហ្វិច ៧៖ ក្នុងរយៈពេល ១០ខែ ឆ្នាំ២០២១ ចិន និង អាមេរិកនៅតែជាទីផ្សារមានសក្ដានុពល ទោះបីជាវិបត្តិជំងឺកូវីដ-១៩នៅតែកំពុងអូសបន្លាយក្ដី (ដកមាស)




ក្រាហ្វិច ៨៖ ទឹកប្រាក់នាំចូលបានធ្លាក់ចុះធៀបនឹងខែមុន ប៉ុន្តែបានកើនឡើងធៀបនឹងខែដូចគ្នាឆ្នាំមុន (ដកមាស)



*ក្រាហ្វិច ៩÷ ក្រៅពីយានយន្ត, ទំហំទឹកប្រាក់នាំចូលទំនិញសំខាន់ៗបានងើបឡើងវិញ (ដកមាស)*




ប្រភព÷ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## ១.៣. ស្ថានភាពវិនិយោគ / Investment

*ក្រាហ្វិច ១០÷ ទុនវិនិយោគបាននិងកំពុងបន្តធ្លាក់ចុះ*




ក្រាហ្វិច ១១÷ ការបង្កើតកម្លាំងពលកម្មថ្មីតាមរយៈការវិនិយោគឯកជនបានធ្លាក់ចុះ




ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ១.៤. វិស័យទេសចរណ៍ /Tourism

*ក្រាហ្វិច ១២÷ ចំនួនភ្ញៀវទេសចរអន្តរជាតិសរុបនៅតែបន្តធ្លាក់ចុះ*




ប្រភព÷ ក្រសួងទេសចរណ៍

## ១.៥. ស្ថានភាពសំណង់ / Construction

*ក្រាហ្វិច ១៣÷ ចំនួនសំណើសុំសាងសង់សរុបនៅតែ និងតម្លៃគម្រោងមានការធ្លាក់ចុះ*




ប្រភព÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices

## ២.១. ថ្លៃប្រេង÷

*ក្រាហ្វិច ១៤÷ និន្នាការថ្លៃប្រេងសាំង និងប្រេងម៉ាស៊ូតលើទីផ្សារកម្ពុជា*




ប្រភព÷ ក្រសួងពាណិជ្ជកម្ម

*ក្រាហ្វិច ១៥ ÷និន្នាការថ្លៃប្រេងសាំងស្តង់ដារលើទីផ្សារអន្តរជាតិ*




ប្រភព÷ ធនាគារពិភពលោក (Pink Sheet)

## ២.២. ថ្លៃអង្ករ÷




*ក្រាហ្វិច ១៦÷ និន្នាការថ្លៃអង្ករស្តង់ដារលើទីផ្សារកម្ពុជា*

ប្រភព÷ ក្រសួងពាណិជ្ជកម្ម




*ក្រាហ្វិច ១៧÷ និន្នាការថ្លៃអង្ករស្តង់ដារលើទីផ្សារអន្តរជាតិ*

ប្រភព÷ World Bank (Pink Sheet)

## ២. ៣. ថ្លៃកៅស៊ូ÷




*ក្រាហ្វិច ១៩÷ និន្នាការថ្លៃកៅស៊ូស្តង់ដារលើទីផ្សារអន្តរជាតិ*

ប្រភព÷ World Bank (Pink Sheet)

**************

**<u>កំណត់សម្គាល់</u>**

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និង STR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០% ។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ប្រើប្រាស់សម្រាប់ ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើង និងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូល ជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំធន់ និងមិនងាយសឹករិចរិល ។ ប្រទេសសំខាន់ៗដែលផលិត កៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាម និងចិន។
- កៅស៊ូ RSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿង និងវេចខ្ចប់ជាបន្ទះ ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុដើម សម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង ។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់ រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល ។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract) ។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នា ទៅតាមប្រភេទដូចជា÷ ប្រភេទប្រេង Brent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai ។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈ ខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់ វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន ។

- WTI 40$^{o}$ API
- Brent 38$^{o}$ API
- Dubai 32$^{o}$ API

*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច*

*អគ្គនាយកដ្ឋានគោលនយោបាយ*

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ.0*

*ទូរស័ព្ទលេខ÷ ០១៧ ៣៦៦ ៥៥៣, ០៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៨:០០ ដល់ ១២:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*